# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ.....០៩៧.....អនក្រ.បក

## អនុក្រឹត្យ

## ស្ដីពី

## ការរៀបចំនិងការប្រព្រឹត្តទៅ របស់សភាពាណិជ្ជកម្មកម្ពុជា

* * * * *

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/ រកត/ ០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលបានប្រកាសអោយប្រើ ច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស / រកម / ០៦៩៥ / ០៣ ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីសភាពាណិជ្ជកម្ម
- បានឃើញ ព្រះរាជក្រមលេខ នស / រកម /០៨០៦/ ០២២ ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៦ ស្ដីពីវិសោធនកម្មមាត្រា ២ និងមាត្រា ១៥ នៃច្បាប់ស្ដីពីសភាពាណិជ្ជកម្ម
- បានឃើញ ព្រះរាជក្រមលេខ នស/ រកម /០១៩៦/ ១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ ១៩៩៧ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញ អនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០២ ស្ដីពីរបៀបរបប និងការរៀបចំ ការបោះឆ្នោតសភាពាណិជ្ជកម្ម
- តាមសំណើ របស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

# សំរេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលដៅកំណត់ការរៀបចំនិងការប្រព្រឹត្តទៅរបស់សភាពាណិជ្ជកម្មកម្ពុជា ។

## ជំពូកទី ២
## តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់សភាពាណិជ្ជកម្មកម្ពុជា

**មាត្រា ២.-**

សភាពាណិជ្ជកម្មខេត្ត-ក្រុងប្រមូលផ្តុំបង្កើតសភាពាណិជ្ជកម្មកម្ពុជា ។

សភាពាណិជ្ជកម្មកម្ពុជាធ្វើសកម្មភាពទូទាំងព្រះរាជាណាចក្រកម្ពុជាហើយគាំទ្រដល់ជំហរ នឹងសកម្មភាពរបស់ពាណិជ្ជកម្មខេត្ត-ក្រុងទាំងឡាយ។ សភាពាណិជ្ជកម្មកម្ពុជា ទទួលបន្ទុកគ្រប់គ្រងសេវាដែលទាក់ទងដល់ពាណិជ្ជកម្ម ឧស្សាហកម្មសិប្បកម្ម កសិកម្ម នឹងអាជីវកម្មផ្សេងទៀត ដែលហួសពីលទ្ធភាពរបស់សភាពាណិជ្ជកម្មខេត្ត-ក្រុង ។

**មាត្រា ៣.-**

ភារៈកិច្ចសភាពាណិជ្ជកម្មកម្ពុជា រួមមាន :

- ធ្វើការទំនាក់ទំនងជាមួយសភាពាណិជ្ជកម្មខេត្ត-ក្រុងនឹងជួយសំរបសំរួលការងារ ធ្វើអោយមានការអភិវឌ្ឍន៍
- ចូលរួមអនុវត្តគោលនយោបាយសេដ្ឋកិច្ចពាណិជ្ជកម្មរបស់រាជរដ្ឋាភិបាដើម្បីបង្កើន សកម្មភាពសេដ្ឋកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា
- ផ្តល់ជូនរាជរដ្ឋាភិបាលនូវយោបល់នឹងពត៌មានស្តីពីសេដ្ឋកិច្ចនិងវិនិយោគ
- ជាដៃគូរចរចាជាមួយរាជរដ្ឋាភិបាល ក្នុងនាមតំណាងសហគមន៍ ពាណិជ្ជកម្ម -ឧស្សាហកម្មសិប្បកម្ម- កសិកម្ម នឹង សេវាកម្ម

- ធ្វើទំនាក់ទំនងជាមួយប្រភពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្រៅប្រទេស
- បំពេញភារកិច្ចដែលហួសពីសមត្ថភាព និងលទ្ធភាពរបស់សភាពាណិជ្ជកម្មខេត្ត-ក្រុង
- ជាសភាប្រឹក្សាធុរកិច្ចយុទ្ធសាស្ត្រសហប្រតិបត្តិការសេដ្ឋកិច្ច អាយ៉េយ៉ាវ៉ាឌី ចាវប្រាយ៉ា មេគង្គ (ACMECS)
- សម្របសម្រួលសភាពាណិជ្ជកម្មខេត្ត-ក្រុង ឱ្យធ្វើសហប្រតិបត្តិការជាមួយគ្នា ដើម្បីប្រើប្រាស់ សក្តានុពលដែលមាននៅតាមខេត្ត-ក្រុង
- ចូលរួមសកម្មភាពជាមួយសភាពាណិជ្ជកម្មក្នុងតំបន់នឹងលើសកលលោក
- បង្កើតនឹងគ្រប់គ្រង គ្រឹះស្ថានធ្វើអាជីវកម្ម នឹងគ្រឹះស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈ
- ចូលរួមក្នុងការដេញថ្លៃជាសាធារណៈ ដើម្បីទទួលភារៈជាសម្បទានិកនៃសំណង់ សាធារណៈការ ឬទទួលបន្ទុកធ្វើសេវាសាធារណៈ
- ធ្វើរបាយការណ៍ប្រចាំឆ្នាំ ពីសកម្មភាពរបស់ខ្លួន ជូនរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។

**មាត្រា ៤.-**

សភាពាណិជ្ជកម្មកម្ពុជាស្ថិតនៅក្រោមអាណាព្យាបាលនៃក្រសួងពាណិជ្ជកម្ម ហើយមានទីស្នាក់ការនៅរាជធានីភ្នំពេញ ។

**មាត្រា ៥.-**

សភាពាណិជ្ជកម្មកម្ពុជាត្រូវបានតំណាងដោយប្រធានរបស់សភាពាណិជ្ជកម្មខេត្ត-ក្រុងនិមួយៗ។

**មាត្រា ៦.-**

សមាជិកសភាពាណិជ្ជកម្មកម្ពុជា មានអាណត្តិ ៣ឆ្នាំហើយត្រូវជ្រើសតាំងសារជាថ្មី នៅក្រោយពេលបោះឆ្នោតជ្រើសតាំងសភាពាណិជ្ជកម្មខេត្ត-ក្រុងនិមួយៗរាល់៣ឆ្នាំម្តង។

សមាជិកសភាពាណិជ្ជកម្មកម្ពុជា ត្រូវបានជ្រើសរើសបង្គ្រប់ នៅពេលមានកន្លែងទំនេរស្របតាមមាត្រា ៥ នៃច្បាប់នេះ ។

**មាត្រា ៧.-**

៣០ថ្ងៃយ៉ាងយូរ ក្រោយពេលបោះឆ្នោតប្រចាំ ៣ឆ្នាំម្តង សភាពាណិជ្ជកម្មខេត្ត-ក្រុងនិមួយៗ ត្រូវចាត់តាំងតំណាងរបស់ខ្លួន អោយធ្វើជាសមាជិកសភាពាណិជ្ជកម្មកម្ពុជា។

**មាត្រា ៨.-**

សភាពាណិជ្ជកម្មកម្ពុជា បំពេញមុខការរបស់ខ្លួនដោយមិនយកប្រាក់បៀវត្ស ឬ ប្រាក់បំណាច់អ្វីឡើយ ។

**មាត្រា ៩.-**

សភាពាណិជ្ជកម្មកម្ពុជា ត្រូវគ្រប់គ្រងដោយការិយាល័យប្រតិបត្តិ ដែលមានសមាជិកដូចខាងក្រោម :

- ប្រធានមួយរូប
- អនុប្រធាន ជាប្រធានសភាពាណិជ្ជកម្មខេត្ត-ក្រុងទាំងអស់
- ហិរញ្ញិកមួយរូប ជ្រើសរើសក្នុងចំណោម សមាជិកជ្រើសតាំងសភាពាណិជ្ជកម្មខេត្ត-ក្រុង ។
- លេខាធិការមួយរូបជ្រើសរើសក្នុងចំណោមសមាជិកជ្រើសតាំងសភាពាណិជ្ជកម្ម ខេត្ត-ក្រុង ។

**មាត្រា ១០.-**

ប្រធានសភាពាណិជ្ជកម្មកម្ពុជា ត្រូវបានជ្រើសរើសក្នុងចំណោមប្រធានសភាពាណិជ្ជកម្មខេត្ត-ក្រុងតាមរយៈការបោះឆ្នោតដោយប្រធានសភាពាណិជ្ជកម្មខេត្ត-ក្រុង ។

ការបោះឆ្នោតជ្រើសរើសប្រធានត្រូវធ្វើជាពីរជុំ ដោយយកតាមសំលេងភាគច្រើនដាច់ខាត ។ ក្នុងករណីមានសម្លេងស្មើគ្នាត្រូវជ្រើសរើសអ្នកមានអាយុច្រើនជាង ។

ចំពោះហិរញ្ញិក និង លេខាធិការ ការបោះឆ្នោតធ្វើតែមួយជុំ ដោយយកតាមសំលេងភាគច្រើនធម្មតា ។

ដោយមានការឯកភាពពីមតិភាគច្រើនពីប្រធានសភាពាណិជ្ជកម្មខេត្តក្រុងប្រធានសភាពាណិជ្ជកម្មកម្ពុជាអាចជ្រើសរើសអនុប្រធានមួយចំនួនថែមទៀត តាមការចាំបាច់ពីក្នុងចំណោមអនុប្រធានសភាពាណិជ្ជកម្មខេត្ត-ក្រុង សំរាប់ជួយការងារ នៅក្នុងសភាពាណិជ្ជកម្មកម្ពុជា ។

**មាត្រា ១១.-**

ប្រធានសភាពាណិជ្ជកម្មកម្ពុជាជាប្រធានការិយាល័យប្រតិបត្តិមានភារៈកិច្ចដឹកនាំសភាពាណិជ្ជកម្មកម្ពុជា នឹងតំណាងអោយសភាពាណិជ្ជកម្មកម្ពុជាចំពោះមុខអាជ្ញាធរ នឹងក្នុងរាល់សកម្មភាពសង្គម ។

ប្រធានត្រូវដឹកនាំរាល់ការប្រជុំ ។ ក្នុងករណីអវត្តមាន ប្រធានត្រូវចាត់តាំងអនុប្រធានម្នាក់ជំនួស ។ ប្រធានសភាពាណិជ្ជកម្ម មានអណត្តិ ៣ឆ្នាំ ។

**មាត្រា ១២.-**

ប្រធានសភាពាណិជ្ជកម្ម ខេត្ត-ក្រុងទាំងអស់ប្រជុំគ្នា ធ្វើការ បោះឆ្នោតជ្រើសរើសការិយាល័យប្រតិបត្តិ

របស់សភាពាណិជ្ជកម្មកម្ពុជា ។ ការបោះឆ្នោតត្រូវបានរៀបចំដោយគណៈកម្មការមួយ ដែលមានសមាជិក ២រូប ៖

- ប្រធាន ជ្រើសរើសយកសមាជិកដែលមានអាយុច្រើនជាងគេ
- លេខា ជ្រើសរើសយកសមាជិកដែលមានអាយុតិចជាងគេ ។

ការបោះឆ្នោតត្រូវមានតំណាងក្រសួងពាណិជ្ជកម្ម ចូលរួម ។

**មាត្រា ១៣.-**

សភាពាណិជ្ជកម្មកម្ពុជា ត្រូវបង្កើតអគ្គនាយកដ្ឋានមួយ ដើម្បីទទួលបន្ទុកគ្រប់គ្រងការងារប្រចាំថ្ងៃ ។

**មាត្រា ១៤.-**

ការបង្កើតនិងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាន និងគណៈកម្មការផ្សេង ៗ ទៀត ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុង ។

## ជំពូកទី ៣
## របៀបរបបធ្វើការងាររបស់សភាពាណិជ្ជកម្មកម្ពុជា

**មាត្រា ១៥.-**

សមាជិកសភាពាណិជ្ជកម្មកម្ពុជាធ្វើការរួមប្រជុំសន្និបាត ៤ដង ក្នុងមួយឆ្នាំ ឬលើសពីនេះតាមការចាំបាច់ តាមសំណើររបស់ប្រធាន ឬតាមសំណើរ របស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មឬតាមសំណើរ មួយភាគបីនៃចំនួនសមាជិករបស់សភាពាណិជ្ជកម្មកម្ពុជា ។

**មាត្រា ១៦.-**

ការប្រជុំសន្និបាតអាចប្រព្រឹត្តទៅបានលុះត្រាតែ មានសមាជិកយ៉ាងតិច ២ភាគ៣ ចូលរួម ។ ក្នុងករណីដែលកូរ៉ូមនេះមិនគ្រប់គ្រាន់ទេប្រធានត្រូវកោះប្រជុំសារជាថ្មី ក្នុងរយៈពេល១០ថ្ងៃក្រោយ ។ ការអញ្ជើញប្រជុំលើកទី២នេះ មិនត្រូវបានកំណត់កូរ៉ុមឡើយ ។

ការសំរេចរបស់សន្និបាត ដែលអាចយកជាការបាន គឺ សម្លេងភាគច្រើនដាច់ខាតរបស់សមាជិកបានចូលរួម លើកលែងតែការសំរេចលើថវិការប្រចាំឆ្នាំរបស់សភាពាណិជ្ជកម្មកម្ពុជា ។

**មាត្រា ១៧.-**

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ត្រូវចាត់មន្ត្រីជាន់ខ្ពស់មួយរូប ឱ្យធ្វើជាមន្ត្រីសំរបសំរួលការងារជាមួយសភាពាណិជ្ជកម្មកម្ពុជា ។ មន្ត្រីសំរបសំរួលការងារ ត្រូវចូលរួមគ្រប់ការប្រជុំនឹងសន្និបាតរបស់សភាពាណិជ្ជកម្មកម្ពុជាក្នុងឋានៈ ជាអ្នកពិគ្រោះយោបល់ ។

## ជំពូកទី ៤
## ហិរញ្ញប្បទាន

**មាត្រា ១៨.-**

ថវិការបស់សភាពាណិជ្ជកម្មកម្ពុជា ត្រូវបានអនុម័តដោយសន្និបាត តាមសំលេងភាគច្រើន២ភាគ ៣ នៃសមាជិកចូលរួម ។

**មាត្រា ១៩.-**

ថវិការបស់សភាពាណិជ្ជកម្មកម្ពុជា មានប្រភពមកពី ៖

- វិភាគទានរបស់សមាជិក
- អំណោយឧបត្ថម្ភទាំងក្នុងនិងក្រៅប្រទេស
- ចំណូលពីការគ្រប់គ្រងគ្រឹះស្ថានសាធារណៈ និងការដេញថ្លៃនានា
- ចំណូលព្រមទាំងវិភាគទានពីប្រភពផ្សេងៗ ។

**មាត្រា ២០.-**

រាល់ការចំណាយត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់ហិរញ្ញិក នឹងដោយមានការយល់ព្រម ពីប្រធានសភាពាណិជ្ជកម្មកម្ពុជា ។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**មាត្រា ២១.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ២២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួងពាក់ព័ន្ធ នឹងអភិបាលខេត្ត-ក្រុងទាំងអស់ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែមករា ឆ្នាំ ២០០៧

ហ៊ុន សែន

**បានយកសេចក្តីជម្រាបជូន**

**សម្តេចនាយករដ្ឋមន្ត្រី**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច-ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រាជកិច្ច
- ឯកសារ-កាលប្បវត្ត